ភាសាវិទ្យានិងវេយ្យាករណ៍ខ្មែរ
កំណត់ត្រាសង្ខេប



សីល សមាធិ បញ្ញា

ចងក្រងដោយ
និស្សិត រី សីលា
https://t.me/SeylaRy

ពាក្យគន្លឹះ

- វេយ្យាករណ៍ ៖ ច្បាប់នៃភាសា
- ភាសា ៖ សម្តី, សូរសំឡេង
- អក្សរ ៖ ស្នាមគំនូសសម្រាប់កត់សូរភាសា។
- អក្សរសាស្ត្រ ៖ កម្រងវិជ្ជា ឬក្បួនខ្នាតដែលសិក្សាពីវិជ្ជាសំខាន់ៗទាក់ទងនឹង
    - ទស្សនវិជ្ជា
    - សាសនវិជ្ជា
    - វិទ្យាសាស្ត្រខាងមនុស្ស
    - វេយ្យាករណ៍
    - កាព្យវិជ្ជា
    - អក្សរសិល្ប៍
- អក្សរសិល្ប៍ ៖ អត្ថបទរឿងប្រលោមប្រកបដោយសិល្បវិធីនិងមានតម្លៃអប់រំ។
  អក្សរសិល្ប៍ជាស្បង់ផងនិងជាសិល្បៈផង។
  ជាស្បង់ព្រោះ
    - តួអង្គជាមនុស្ស

- ឆ្លុះបញ្ចាំងពីតថភាពសង្គម
- លើកយកបញ្ហាមនុស្សមកចោទនិងដោះស្រាយ

ជា**សិល្ប:**ព្រោះជាអត្ថបទប្រកបដោយសិល្ប៏ភាពគួរជាទីចាប់ចិត្តនៃអ្នកអាន។



អំពីអក្ខរ

-អក្សរ មានលក្ខណៈ២យ៉ាងគឺ មិនរឹងគឹទន់ និងប្រើមិនចេះអស់។

-អក្សរ សំដៅដល់ ព្យញ្ជនៈ ស្រៈ និងវណ្ណយុត្តិ។

-ក្នុងការសិក្សាពីបែបនៃអក្សរ(អក្ខរវិធី) ត្រូវឈរលើគោលការណ៍៣គឺ

- សញ្ញា
- ឈ្មោះ
- សូរ ។

-ព្យញ្ជនៈ គឺសូរដែលបន្លឺឡើងដោយមានទំនប់តិចឬច្រើនអាស្រ័យទៅតាមរង្វង់ខ្យល់ដែលចេញពីសួត។ សូរព្យញ្ជនៈមិនអាចបន្លឺបានច្បាស់ទេ បើសិនជាគ្មានសូរស្រៈនៅអាស្រ័យជាមួយ។

-ស្រៈ គឺសូរដែលបន្លឺឡើងដោយគ្មានទំនប់ អាចបញ្ចេញសំឡេងខ្លួនឯងបានផង អាចនាំព្យញ្ជនៈឱ្យចេញសំឡេងបាន មានសូរឮតាមរំពងព្យញ្ជនៈផង។

-វណ្ណយុត្ត ជាគ្រឿងប្រដាប់សម្រាប់ប្រើផ្សំជាមួយនឹងអក្សរ មាននាទីកែលម្អៀងសូរស្រៈនិងព្យញ្ជនៈ ឱ្យបែរសូរតាមត្រូវការ។

-វណ្ណវាទ ជាប្រភេទមួយនៃសិប្បសញ្ញាដែលមានលក្ខណៈខុសពីវណ្ណយុត្តដោយគ្មានតួនាទីក្នុងការប្រកបសូរ។ វណ្ណវាទមួយចំនួនមានដូចជា ៈ ។ ! ? , «...» ជាដើម ដែលមានទំនាក់ទំនងទៅនឹងដំណកឃ្លា។ កន្លងមក គេហៅសញ្ញាទាំងនេះថា សញ្ញាប្រយោគ សញ្ញាល្បះ ឬខណ្ឌសញ្ញា។

-សញ្ញាល្បះ គឺសញ្ញាដែលប្រើក្នុងល្បះ។

-ខណ្ឌសញ្ញា សញ្ញាសម្រាប់ប្រើរាំងឃ្លាឬសង្កាត់នៃសេចក្តីនីមួយៗឱ្យដាច់ស្រឡះដោយឡែកពីគ្នា មានដូចជា ។ ! ? , ; ជាដើម។

ព.ស.ហ.ស
សីល សមាធិ បញ្ញា

១.១ ព្យញ្ជនៈនិងជើងព្យញ្ជនៈ

ព្យញ្ជនៈខ្មែរ៣៣តួ

វគ្គក	ក	ខ	គ	ឃ	ង
វគ្គច	ច	ឆ	ជ	ឈ	ញ
វគ្គដ	ដ	ឋ	ឌ	ឍ	ណ
វគ្គត	ត	ថ	ទ	ធ	ន
វគ្គប	ប	ផ	ព	ភ	ម
វគ្គសេស	យ	រ	ល	វ	ស	ហ	ឡ	អ

ជើងព្យញ្ជនៈ៣២តួ

◌	◌	◌	◌	◌
◌	◌	◌	◌	◌
◌	◌	◌	◌	◌
◌	◌	◌	◌	◌

ព.ស.ហ.ស
សីល សមាធិ បញ្ញា

◌ៀ ◌ុ ◌ូ ◌ួ ◌ឹ

◌ៀ ◌ែ ◌ៃ ◌ោ ◌ៅ ◌ំ ◌ះ ។

២.២ សូរព្យញ្ជនៈខ្មែរមាន២១សូរ

ក-គ១ (K) ខ-ឃ២ (Kh) ង៣ (Ng) ច-ជ៤ (C) ឆ-ឈ៥ (Ch) ញ៦ (Nh)

ដ-ឌ៧ (D) ឋ-ថ-ឍ-ធ៨ (Th) ណ-ន៩ (N)

ត-ទ១0 (T) ប-ប៊១១ (B) ផ-ភ១២ (Ph)

ប៉-ព១៣ (P) ម(M), យ(J), រ(R), ល-ឡ(L), វ(V), ស(S), ហ(H), អ(?)

២.៣ មូលភេទអ-អ៊

ព្យញ្ជនៈពួកអ១៥តួ

ក ខ ច ឆ

ដ ឋ ណ

ត ថ ប ផ ស ហ ឡ អ

ព្យញ្ជនៈពួកអ៊១៨តួ

គ ឃ ង ជ ឈ ញ

ឌ ឍ ទ ធ ន

ព ភ ម យ រ ល វ

ព.ស.ហ.ស
សីល សមាធិ បញ្ញា

២.៤ ព្យញ្ជនៈគូគ្នា(សិថិល-ធនិត)

ក-ខ១ គ-ឃ២ ច-ឆ៣ ជ-ឈ៤ ដ-ឋ៥ ឌ-ឍ៦ ត-ថ៧ ទ-ធ៨ ប-ផ៩ ព-ភ១០

២.៥ ព្យញ្ជនៈសម្លាប់

- ព្យញ្ជនៈសម្លាប់ដោយមូសិកទន្តមាន៖

ង៑ ញ៑ (ន៑) ប៑* ម៑ យ៑ រ៑ (ល៑) វ៑

*សម្គាល់៖ ប មិនមែនជាព្យញ្ជនៈសម្លាប់ទេ ព្រោះវាពុំបានផ្លាស់ប្តូរមូលភេទឡើយ គ្រាន់តែប្តូរសូរប៉ុណ្ណោះ។

- ព្យញ្ជនៈសម្លាប់ដោយត្រីសព្ទមាន៖ ប៊ ស៊ ហ៊ អ៊

ព្យញ្ជនៈសម្លាប់រងទំនាញសូរ(ពួកអ៊ិទៅពួកអ ពួកអទៅជាអ៊ិ)៖

ឧទាហរណ៍៖ ក្ងាន ក្រញាញ់ ខ្នាត របាំ ក្រមា ក្រយា កម្រៃ សាលា ច្រវា

២.៦ ព្យញ្ជនៈផ្ញើជើង(ព្យញ្ជនៈផ្សំ)

- ព្យ.ទី១និងទី២មានមូលភេទអនាំឱ្យព្យ.ផ្សំមានមូលភេទអ

  ឧ. ក្ឋ ខ្ឋ ឆ្ឋ ថ្ឋ

- ព្យ.ទី១និងទី២មានមូលភេទអ៊ីនាំឱ្យព្យ.ផ្សំមានមូលអ៊ី

  ឧ. គ្ន ឃ្ន ជ្រ ធ្ង

- ព្យ.ទី១និងទី២មានមូលភេទខុសគ្នា ហើយគ្មានព្យ.ណាមួយជាព្យ.សម្លាប់ នោះព្យ.ផ្សំមានមូលភេទដូចព្យ.ទី២(ជើងព្យ.)

  ឧ. ខ្ម ស្ត

- ព្យ.ទី១និងទី២មានមូលភេទខុសគ្នា ហើយមានព្យ.ណាមួយជាព្យ.សម្លាប់ នោះព្យ.ផ្សំមានមូលភេទដូចព្យ.ដែលមិនមែនជាព្យ.សម្លាប់ (ទំនាញសូរ)

  ឧ. ម្ត ក្រ ង្ខ ខ្ម ច្ន? ស្ល?

២.៧ ព្យញ្ជនៈខ្យល់ឬតួប្រកប

- ព្យ.នៅខាងចុងពាក្យហៅថាព្យ.ប្រកប។ វាមានឥទ្ធិពលក្នុងការបង្វែរសូរស្រៈ

  ឧ. ចាន កុក ស្លាប កែវ

- ចំពោះពាក្យខ្មែរសុទ្ធ ព្យញ្ជនៈប្រកបគឺព្យ.នៅដើមវគ្គនិងចុងវគ្គនីមួយៗនិងព្យ.នៃវគ្គសេស៥តួ(យ-រ-ល-វ-ស)លើកលែងតែ«ដ»និង«ណ»ចេញ២តួចេញ។

  *វគ្គក(ក-ង) វគ្គច(ច-ញ) វគ្គត(ត-ន) វគ្គប(ប-ម)

ព.ស.ហ.ស
សីល សមាធិ បញ្ញា

អំពីស្រៈ

២.១ ស្រៈនិស្ស័យ២១តួតាមវចនានុក្រមខ្មែរ

ស្រៈអ ◌ា ◌ិ ◌ី ◌ឹ ◌ឺ ◌ុ ◌ូ ◌ួ ◌ើ ◌ឿ ◌ៀ ◌ែ ◌ៃ ◌ោ ◌ៅ ◌ុំ ◌ំ ◌ាំ ◌ះ

ឈ្មោះសញ្ញាខ្លះដែលប្រើក្នុងស្រៈ

- ◌ា ហៅថា ទាញយារ ប្រើក្នុងស្រៈ អា អោ អៅ និងអាំ
- ◌ុ ហៅថា រុកជើង ប្រើក្នុងស្រៈអុនិងអុំ
- ◌ែ ហៅថា បាំងឈើ ប្រើក្នុងស្រៈអើ អឿ អៀ អេ អែ អៃ អោ អៅ
- ◌ំ ហៅថាដំលើឬនិគ្គហិត ប្រើក្នុងស្រៈអុំ អំ អាំ និងអឹ
- ◌ះ ហៅថារះមុខ តាមសំស្ក្រឹតហៅថា វិសជ៌នីយ ឬវិសគ៌ (ក្នុងបាលីគ្មានទេ)ប្រើក្នុងស្រៈអ (ជ្រៈ) អិ(ជិះ) អឹ(ឆ្កឹះ) អុ (ចុះ) អេ(ចេះ) អៃ(កៃះ) និងអោ(តោះ)។

ឧ. ច្រែះ ច្រៃស ច្រេស

ស្រៈ ខុសពី ស្រៈ

២.២ ស្រៈនិស្ស័យបន្ថែមបច្ចុប្បន្ន

ិ◌ះ ី◌ះ ៃ◌ះ ុ◌ះ ែ◌ះ ៅ◌ះ

ឧ. ជិះ ចង្កឹះ ច្រៃះ

២.៣ ស្រៈពេញតួ

អ អា ??

ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឲ

ព.ស.ហ.ស
សីល សមាធិ បញ្ញា

អំពីវណ្ណយុត្តិ

៣.១ វណ្ណយុត្តតាមវចនានុក្រមខ្មែរ

វណ្ណយុត្ត(វណ្ណយុត្តិ) ជាគ្រឿងប្រដាប់សម្រាប់ប្រើផ្សំជាមួយនឹងអក្សរ;

វណ្ណយុត្តសម្រាប់ប្រើក្នុងភាសាខ្មែរមាន ១៩ យ៉ាងគឺ

១- វិសជ៌នី ឬ វិសគ៌: ឬក៏រៈមុខ (ៈ);

ជិៈ(ជិស) ឆ្គីៈ(ឆ្គីស) ព្រៃៈ(ព្រៃស)

២- មូសិកទន្ត ឬ ធ្មេញកណ្តុរ (៉) ;

៣- ត្រីសព្ទ (៊);

៤- ទណ្ឌឃាត ឬ បដិសេធ (៍) ;

៥- របាទ ឬ រេផៈ (៎);

៦- រស្សសញ្ញា ឬ បន្តក់ (៏);

៧- សំយោគសញ្ញា (័);

៨- លេខទោ ឬ អាមេឌិតសញ្ញា (ៗ);

៩- លេខអស្តា (៑);

១០- កាកបាទ ឬ ជើងក្អែក (+);

ព.ស.ហ.ស
សីល សមាធិ បញ្ញា

១១- កុក្កុដនេត្រ ឬ ភ្នែកមាន់ (๐);

១២- របៈ(ฯ); ១៣- របៈចប់ ឬ របៈបរិយោសាន (๚);

១៤- គោមូត្រ (๛);

១៥- វ៉ាត់ ឬ គាប (ฯ);

១៦- រង្វង់សញ្ញា (–);

១៧- មច្ឆណ្ឌាសញ្ញា ឬ ពងត្រី (. . .) ;

១៨- បេយ្យាល (ฯ បេ ฯ) ឬ (ฯ ល ฯ);

១៩- យុគលពិន្ទុ (:)

*ក្នុងវចនានុក្រមនេះ មានប្រើវណ្ណយុត្តរបស់អឺរ៉ុបផង គឺ . , ; : ? ! = < > " " ( ) សម្រួលតាមសម័យនិយម (ដែលក្នុងសម័យបច្ចុប្បន្នបានឲ្យឈ្មោះជា សំ. បា. ឬជាខ្មែរអស់ហើយ) ។

៣.២ វណ្ណយុត្តតាមលោកអៀវកើស

តាមលោកអៀវកើស៖ វណ្ណយុត្ត(វណ្ណយុត្តិ) ជាសញ្ញាសម្រាប់កែលម្អៀងសំឡេងស្រៈនិងព្យញ្ជនៈឱ្យបែរទៅតាមត្រូវការ។

វណ្ណយុត្តសម្រាប់ប្រើក្នុងភាសាខ្មែរមាន៩

១- វិសជ៌នី ឬ វិសគ៌ៈ ឬក៏រៈមុខ (ៈ);

ឧ. ច្រែះ ឆ្ពឹះ ជិះ

២- មូសិកទន្ត ឬ ធ្មេញកណ្តុរ (៉) ;

៣- ត្រីសព្ទ (៊); ប៊ ស៊ ហ៊ អ៊

៤- ទណ្ឌឃាត ឬ បដិសេធ (៌) ;

ឧ. ប្រយោជន៍ សៅរ៍ ព្រហស្បត៍ អាទ៍ ដើមពោធ៍

៥- របាទ ឬ រេផៈ (៌);

ឧ. ទុគ៌ត(ទុរគត) មត៌ក(មរតក)

៦- រស្សសញ្ញា ឬ បន្តក់ (៌);

ឧ. កាក់

៧- សំយោគសញ្ញា (៌);

ឧ. អាសយដ្ឋាន ទូរសព្ទ ក្របខណ្ឌ ឧបសម្ពន្ធ សោភ័ណ សោភណភាព

កុំព្យូទ័រ (Computer)

(លើកលែង) ប្រព័ន្ធ ប្រពន្ធ

៨- លេខទោ ឬ អាមេណ្ឌិតសញ្ញា (ៗ);

ព.ស.ហ.ស
សីល សមាធិ បញ្ញា

ឧ. នានា

៩- លេខអស្តា (៏); ឧ. ក៏ ដ៏

តាមលោកអៀវកើស ក្រៅពីសញ្ញាខាងលើ សុទ្ធតែជា ខណ្ឌសញ្ញា មាន

១.កុក្កុដនេត្រ ឬ ភ្នែកមាន់ (๏);

២.គោមូត្រ (៸);

៣.ល្បះ(របះ)(។);

៤.ល្បះចប់(របះចប់ ឬ របះបរិយោសាន) (។៕);

៥.បេយ្យាល(។បេ។ ឬ ។ល។)ឬសង្ខេបសញ្ញា(។ន.ទ.។)

៦.កាកបាទឬជើងក្អែក(+)

៧.រ៉ាត់ ឬ គាប ឬឃ្នាប?({...})

៨.រង់ក្រចក(...)

៩.រង់ក្រចកធំ/រង់ក្រចកជ្រុង([...])

១០.រជ្ជុសញ្ញា (–);

១១.សហសញ្ញា/យតិភង្គ(-)

១២.ចំណុច (.)

ព.ស.ហ.ស
សីល សមាធិ បញ្ញា

១៣.ក្បៀស (,)

១៤.ចំណុចក្បៀស (;)

១៥.មច្ឆណ្ហាសញ្ញា ឬ ពងក្រី ឬ ចំណុចរាយ (. . .)

១៦.សញ្ញាសួរ (?)

១៧.ឧទានសញ្ញា (!)

១៨.ដំលើឬចំណុចពីរ? (ះ)

១៩.អញ្ញប្រកាស («»)



ព្យាង្គ

ពាក្យគន្លឹះ

-សទ្ទ គឺជាឯកតាតូចបំផុតនៃពាក្យ មិនអាចបំបែកបាន ហើយគ្មានន័យ។

ឧ. គិត មាន៣សទ្ទ គឺ «គ», «ិ» និង«ត»។

-ព្យាង្គ ជាសូររួមនៃសទ្ទបង្កើតបានមួយបន្សាយសំឡេង។

-ពាក្យ គឺជាសូររួមនៃសទ្ទ បង្កើតបានមួយបន្សាយសំឡេង ពីរបន្សាយសំឡេង បីបន្សាយសំឡេង ឬបួនបន្សាយសំឡេង... ហើយមានន័យគ្រប់គ្រាន់ស្តាប់បាន។

-ឃ្លា គឺសេចក្តីមួយសង្កាត់ៗនៅក្នុងល្បះ។

-ល្បះ គឺជាបន្សំរវាងកន្សោមពាក្យ មានន័យគ្រប់គ្រាន់ស្តាប់បាន បញ្ចប់ដោយសញ្ញាខណ្ឌ សញ្ញសួរ ឬសញ្ញាឧទាន។

-កថាខណ្ឌ គឺជាដំណើរពាក្យដែលមានសេចក្តីគ្រប់គ្រាន់មួយសង្កាត់ៗ(មានគំនិតសំខាន់១)។

១.ទម្រង់ព្យាង្គ

ព្យាង្គក្នុងភាសាខ្មែរនីមួយៗ មានទម្រង់ជាសទ្ទដូចជា៖

- ពស ៖ កា សី កិ ចឹ
- ពសពៈ គិត កាប កិត ចឹត

- ពពសៈ ខ្ចី ស្វា
- ពពសពៈ ផ្តើម ស្រួល

២. ព្យាង្គបិទព្យាង្គបើក

ផ្អែកលើទម្រង់ខាងលើ ព្យាង្គខ្មែរមាន២ប្រភេទគឺ ព្យាង្គបិទនិងព្យាង្គបើក។

- ព្យាង្គបិទ មានទម្រង់«ពសព», «ពពសព» និង«សព»
- ព្យាង្គបើក មានទម្រង់ «ពស», «ពពស», «ស»។

ព.ស.ហ.ស
សីល សមាធិ បញ្ញា

អក្សរតម្រួត?ព្យាង្គតំរួត?

អក្សរ=ព្យញ្ជនៈ+ស្រៈ+វណ្ណយុត្តិ

ឧ. សំ (អក្សរតម្រួត)

ស្ត (ព្យាង្គតំរួត)

សម្ត (តំរួតព្យាង្គ)



គា

ចម្លើយ < ឆ្លើយ

ចំលើយ? ចំឡើយ?

ស្ល > សម្ល ឬសំល?

ព.ស.ហ.ស
សីល សមាធិ បញ្ញា

ប្រភេទព្យាង្គ

-សំរាយ គឺជាបញ្ញត្តិមួយនៃវេយ្យាករណ៍អន្តរកម្មនិយម ដែលស្តែងពី *ព្យាង្គរាយ* និង *រាយព្យាង្គ* ។

-តំរួត គឺជាបញ្ញត្តិមួយនៃវេយ្យាករណ៍អន្តរកម្មនិយម ដែលស្តែងពីវិធីតំរួតព្យាង្គនិងវិធីកាត់ ព្រមទាំងពីព្យាង្គទាំងអស់ លើកលែងតែព្យាង្គរាយ។

-ព្យាង្គរាយ ជាព្យាង្គកើតឡើងដោយគ្មានការប្រកបសូរវាងព្យញ្ជនៈនឹងព្យញ្ជនៈមុននឹងប្រកបសូរនៃស្រៈ។ ឧ. រាយ ដើរ គោ ទាប ស ទ្បាន លឿន ...។

-ព្យាង្គតំរួត ជាព្យាង្គដែលកើតឡើងដោយមានការប្រកបសូរវាងព្យញ្ជនៈនឹងព្យញ្ជនៈ មុននឹងការប្រកបសូរនៃស្រៈ។ ឧ. ស្លា គ្រាប់ ត្រួត ល្អ ...។

*ព្យាង្គតំរួតខុសពីអក្សរតម្រួត។+

-ព្យាង្គផ្ងើជើង ជាព្យាង្គដែលមានលក្ខណៈដូចព្យាង្គរាយដែរ តែមានជើងព្យញ្ជនៈមួយផ្ងើនៅព្យញ្ជនៈចុងព្យាង្គ ហើយជើងព្យញ្ជនៈនោះគ្មានការប្រកបសូរទេ។ ឧ. ពន្ធ អង្គ ពុម្ព វិចិត្រ ...។

-ព្យាង្គកប់ ជាព្យាង្គដែលមានសូរព្យញ្ជនៈដើមព្យាង្គកត់ត្រាដោយជើងព្យញ្ជនៈដាក់កប់នៅក្រោមព្យញ្ជនៈមួយដោយគ្មានការប្រកបសូរ។ ឧ. ហ្ម អ្នក ហ្នឹង ...។

-ព្យាង្គលឹប ជាព្យាង្គដែលសូរព្យញ្ជនៈចុងព្យាង្គកត់ត្រាដោយជើងព្យញ្ជនៈដាក់ក្រោមព្យញ្ជនៈមួយដោយគ្មានការប្រកបសូរ។ ឧ. ព្រហ្មណ៍ ព្រហ្ម ...។

-ព្យាង្គហើរ ជាព្យាង្គដែលសូររបស់វាត្រូវបានកត់ត្រាដោយសញ្ញារបាទនៅលើព្យញ្ជនៈណាមួយ ។ ឧ. បព៌ត ទុគ៌ត ...។

-ព្យាង្គកាត់ ជាព្យាង្គដែលមានលក្ខណៈជាព្យាង្គតម្រួតផងជាព្យាង្គធ្ងើជើងផង ពោលគឺដើមព្យាង្គកើតដោយការប្រកបសូរ រវាងព្យញ្ជនៈនិងព្យញ្ជនៈ ហើយចុងព្យាង្គកត់ដោយជើងព្យញ្ជនៈដាក់លើព្យញ្ជនៈមួយដោយគ្មានការប្រកបសូរ។ ឧ. ស្តម្ភ ទ្រព្យ ព្យាង្គ ...។

-យោង : ច័ន្ទ សំណព្វ សំណេរនិងអក្ខរាវិរុទ្ធខ្មែរ

ព.ស.ហ.ស
សីល សមាធិ បញ្ញា

វិធីសំណេរពាក្យ

១. វិធីរាយព្យាង្គ

-រាយព្យាង្គ ជាវិធីមួយនៃការសរសេរពាក្យច្រើនព្យាង្គ ដោយដាក់ព្យាង្គបន្តបន្ទាប់គ្នា និងគ្មានការត្រួតព្យញ្ជនៈចុងព្យាង្គនៃព្យាង្គទី១នឹងព្យញ្ជនៈដើមព្យាង្គនៃព្យាង្គទី២នោះទេ ទោះបីព្យាង្គនីមួយៗជាព្យាង្គអ្វីក៏ដោយចុះ។

ឧ. គគ្រឹកគគ្រែង រុះរោយ ក្រីក្រ ស្រស់ស្រាយ ប្រិមប្រិយ ...។

ក្រ = ព្យាង្គតម្រួត

ក្រីក្រ = រាយព្យាង្គ

២. វិធីតំរួតព្យាង្គ

-តំរួតព្យាង្គ ជាវិធីមួយនៃការសរសេរពាក្យពីរព្យាង្គ ដោយមានការត្រួតព្យញ្ជនៈចុងព្យាង្គនៃព្យាង្គទី១ទៅនឹងព្យញ្ជនៈដើមព្យាង្គនៃព្យាង្គទី២។

ឧ. បង្កើត បណ្តើរ ពន្យល់ ជញ្ជួន សង្គ្រាម អន្លាយ ...។

***បញ្ជាក់៖**

-ព្យាង្គរាយ ជាព្យាង្គកើតឡើងដោយគ្មានការប្រកបសូរវាងព្យញ្ជនៈនឹងព្យញ្ជនៈមុននឹងប្រកបសូរនៃស្រៈ។ ឧ. រាយ ដើរ គោ ទាប ស ឡាន លឿន ...។

-ព្យាង្គតម្រួត ជាព្យាង្គដែលកើតឡើងដោយមានការប្រកបសូរវាងព្យញ្ជនៈនឹងព្យញ្ជនៈ មុននឹងការប្រកបសូរនៃស្រៈ។ វាអាចមានទម្រង់ «ពពស» «ពពសព» ។ ឧ. ស្លា គ្រាប់ ត្រួត ល្អ ...។

៣. វិធីកាត់ៈ ជាវិធីមួយនៃការសរសេរពាក្យចាប់ពីបីព្យាង្គឡើងទៅ ដោយការសរសេរពាក្យនោះមានរួមទាំងវិធីរាយព្យាង្គផង និងតំរួតព្យាង្គផង ទោះបីព្យាង្គនីមួយៗជាព្យាង្គប្រភេទអ្វីក៏ដោយចុះ។

ឧ. វេយ្យាករណ៍ អណ្តែតអណ្តូង មហាសង្គ្រាន្ត សង្គ្រាមលោក កណ្តាចកណ្តែង អណ្តែតអណ្តូង បង្អែបង្អង់ បណ្ណាល័យ ។ល។

ព.ស.ហ.ស
សីល សមាធិ បញ្ញា

គោលការណ៍សំណេរពាក្យខ្មែរ

៣.១ គោលការណ៍អាស្រ័យឫស (តាមវចនានុក្រមខ្មែរ)

គោលការណ៍អាស្រ័យឫស បានចែងថា

១. បើពាក្យឫសជាព្យាង្គតម្រួត ពាក្យកម្លាយត្រូវសរសេរជាតម្រួតព្យាង្គ

ឧ. ស្ល > សម្ល

ឆ្លើយ > ចម្លើយ

ស្លាប់ > សម្លាប់

សំឡេង

តែង > ត្មែង ?

ជួញ > ឈ្មួញ ?

ចាំ > ឆ្មាំ ?

ស្ពារ > ចម្ការ

២. បើពាក្យឫសជាព្យាង្គរាយ ពាក្យកម្លាយត្រូវសរសេរជារាយព្យាង្គ

ឧ. ចេះ > ចំណេះ, ខឹង>កំហឹង, ឆេះ>ចំហេះ, ជាញ>ជំនាញ, ចត>ចំណត

ខ្ពស់ > កម្ពស់

តក់>តំណក់, តំណក់ទឹក

ដក់>ដំណក់, ដំណក់ទឹក

*ករណីលើកលែង៖

-ចំពោះ (ចម្ពោះ)< ឆ្ពោះ ?

-សំណើ (សម្តើ)< ស្តើ ?

សើ > សំណើ

ស្តើ > សម្តើ

៣.២ គោលការណ៍អាស្រ័យផ្តុត (តាមបណ្ឌិត ច័ន្ទ សំណព្វ)

ផ្ទុយទៅនឹងគោលការណ៍អាស្រ័យឫស គោលការណ៍អាស្រ័យផ្តុត ចែងថា

-ពាក្យមួយអាចសរសេរបានច្រើនបែបច្រើនយ៉ាងដោយមិនមានខុស អាស្រ័យលើសញ្ញាកត់សូរនៃផ្តុត់ដែលភ្ជាប់ទៅនឹងពាក្យឫស។

ឧ. ស្តារ > [អ៉ម] + ស្តារ > ចម្តារ, ចំការ

*ចម្តារ ផ្តុត់[អ៉ម] ត្រូវបានកត់សូរដោយព្យញ្ជនៈ«ម»

*ចំការ ផ្តុត់[អ៉ម] ត្រូវបានកត់សូរដោយសញ្ញាដំលើឬស្រៈ«ុំ»

៤.១ ថ្នាក់ពាក្យ (Parts of Speech/Word Classes)

៤.១.១ ថ្នាក់នាម គឺជាពាក្យសម្តីសម្តែងប្រាប់ឈ្មោះ មនុស្ស សត្វ រុក្ខជាតិ វត្ថុ ទីកន្លែង ឬភាវៈផ្សេង

- នាមសាធារណ៍(Common Nouns) គឺជានាមសម្តែងឈ្មោះទូទៅ មិនចំពោះ

  ឧ. ពួខ្ញុំដឹកគោតាមភ្លឺស្រែ។

- នាមអសាធារណ៍ (Proper Nouns) គឺជានាមសម្តែងឈ្មោះប្រាកដ ចំពោះ មិនទូទៅ។

  ឧ. លីននិងទេម្មី គឺជាមិត្តរួមថ្នាក់នឹងគ្នា។

- នាមករណ៍ (Gerund) គឺជានាមសម្តែងសភាព(សភាវៈនាម) ឬសកម្ម(សកម្មនាម)។ នាមករណ៍កើតចេញពី
  - កិរិយាសព្ទ
    - តាមវិធីកម្លាយផ្នត់

      ឧ. ធ្វើ > ទង្វើ

      ដើរ > ដំណើរ

    - តាមវិធីបន្ថែមដើមដោយបុព្វបទ(ការ/សេចក្តី/ភាព)

      ឧ. ការដើរ សេចក្តីសង្ឃឹម
  - គុណនាមប្រក្រតី

- តាមវិធីកម្លាយផ្នត់

  ឧ. កាច > កំណាច

  ខ្ពស់ > កម្ពស់

- តាមវិធីបន្ថែមដើម

  ឧ. សុខ > សេចក្តីសុខ

  ថ្លៃថ្នូរ > សេចក្តីថ្លៃថ្នូរ

- នាមការក៍ (Nouns of Profession) គឺជានាមសម្តែងអ្នកធ្វើអំពើ ឬអ្នកមានសភាពលក្ខណៈបែបណាមួយ។ វាកើតចេញពី
  - កិរិយាសព្ទ
    - តាមវិធីកម្លាយផ្នត់

      ឧ. ចាំ > ឆ្មាំ, ជួញ>ឈ្មួញ, កាន់>ខ្មាន់, តែង>ត្មែង
    - តាមវិធីបន្ថែមដើម

      ឧ. យាម > អ្នកយាម
    - តាមវិធីបន្ថែមចុង

      ឧ. កសិករ ពាណិជ្ជករ កម្មករ ស្ថាបត្យករ វិស្វករ

ព.ស.ហ.ស
សល សមាធិ បញ្ញា

ទស្សនវិទូ ចិត្តវិទូ, នាយក នាយិកា សកលវិទ្យាការ, កុមារ, កុមារី

- គុណនាមប្រក្រតី

  ឧ. អ្នកស្លូត អ្នកកាច

- នាម

  ឧ. អ្នកស្រែ អ្នកក្រុង អ្នកចម្ការ

- នាមជីវចល (Animate Nouns) គឺនាមបង្ហាញពីភាវៈមានជីវិត(មានវិញ្ញាណ)។
- នាមអជីវចល (Inanimate Nouns) គឺនាមបង្ហាញពីភាវៈគ្មានជីវិត (ឥតវិញ្ញាណ)។
- នាមរូបី (Concrete Nouns) គឺនាមដែលដឹងដោយឥន្ទ្រិយទាំងប្រាំ និងចិត្តរបស់ មនុស្ស។
- នាមអរូបី (abstract nouns) គឺនាមបង្ហាញពីអំពើ គុណភាព ភាព ឬលក្ខណៈណាមួយរបស់មនុស្ស សត្វ និងវត្ថុ។

  ឧ. ទម្ងន់ ម៉ាស

- នាមរនាប់ គឺនាមសម្គាល់នូវឯកតាសម្រាប់រាប់ចំនួន វាឈរនៅខាងស្តាំគុណនាម(គុណនាមចំនួន)។

  ឧ. ពីរនាក់ ពីរក្បាល

- នាមផ្សំ (Compound Nouns) គឺនាមកើតឡើងដោយបន្សំរវាងពាក្យមួយនិងពាក្យមួយទៀត។ វាអាចកើតឡើងដោយបន្សំរវាងនាមនិងនាម នាមនិងកិរិយាសព្ទ នាមនិងគុណនាម នាមនិងនាមនិងនាម ...។

ឧ. សៀវភៅភាសាខ្មែរ

- សមូហនាម (Collective Nouns)

  ឧ. គណបក្ស

៤.១.១.១. មុខងារនៃនាម (functions of nouns)

- មុខងារជាប្រធាន (subject)

  ឧ. លីននិយាយ។

- មុខងារជាកម្មបទផ្ទាល់ (direct object)

  ឧ. ទេម៉ីអានសៀវភៅ។

- មុខងារជាកម្មបទមិនផ្ទាល់ (indirect object)

  ឧ. ខ្ញុំឱ្យសៀវភៅដល់លីន។ I gave Lin a book. = I give a book to Lin.

  លីននិយាយអំពីវេយ្យាករណ៍ខ្មែរ។

- មុខងារជាកម្មបទទី២

  ឧ. ខ្ញុំឱ្យទេម៉ីខ្ចីសៀវភៅ។

- មុខងារជាកម្មបំពេញបទ

  ឧ. នេះជាសៀវភៅរបស់លីន។

ព.ស.ម.ស
សីល សមាធិ បញ្ញា

រាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា

- មុខងារជាឧបបទ (apposition)

ឧ. សីហា ប្អូនខ្ញុំរៀនថ្នាក់ទី៩។

Seyha, my brother, studies in grade 9.

- មុខងារជាគុណប្រធាន (complement)

ឧ. យើងជានិស្សិតជំនាញអក្សរសាស្ត្រខ្មែរ។

- មុខងារជាពង្រីកមិនរណប

ឧ. ទេម៉ីនិងលីនរៀននៅបន្ទប់លេខ៣។

*នាមខ្មែរមិនមានលិង្គនិងវចន:ទេ។

-លិង្គ មានភេទស្រី ភេទប្រុស អភេទ

ឧ. កុមារា កុមារី នាយក នាយិកា កម្មករ កម្មការិនី

ក្មេងប្រុស ក្មេងស្រី ឪពុក ម្តាយ ជីតា ជីដូន

-វចន:

ឧ. មនុស្ស មនុស្សា man men

-មនុស្សម្នាក់ មនុស្សច្រើន

ត.ស.ហ.ស
សីល សមាធិ បញ្ញា

❖ កន្សោមនាម (Noun Phrase) ៖

ឧ. លីននិងទេមី សៀវភៅខ្ញុំ ចានដែក កុំព្យូទ័រលើតុ

៤.១.២ គុណនាម

៤.១.២.១ ប្រភេទគុណនាម

- គុណនាមប្រក្រតី

  ឧ. សៀវភៅល្អ ចេកទុំ

- គុណនាមសំណួរ

  ឧ. តើអ្នកមានសៀវភៅប៉ុន្មានក្បាល?

  តើគាត់ចូលចិត្តមួបអ្វី?

  តើគាត់ចូលចិត្តអ្វី?

- គុណនាមចំនួន

  - ចំនួនរាប់(Cardinal Number)

    ឧ. សៀវភៅពីរក្បាល two books

  - ចំនួនរៀប(Ordinal Number)

ឧ. និស្សិតឆ្នាំទី៣ Third Year Student

- គុណនាមចង្អុល (Demonstrative adjective)

ឧ. សៀវភៅនេះជារបស់ខ្ញុំ។ (គុ.ចង្អុល)

នេះជាសៀវភៅរបស់ខ្ញុំ។ (សព្វ.ចង្អុល)

- គុណនាមមិនច្បាស់

ឧ. ខ្ញុំញ៉ាំម្ហូបអ្វីក៏បាន។ (គុ.)

ខ្ញុំញ៉ាំអ្វីក៏បាន។ (សព្វ.)

សិស្សបួនដប់នាក់

- គុណនាមកម្មសិទ្ធិ

ឧ. ប៊ិកនេះជារបស់ខ្ញុំ។ This pen is mine.

ប៊ិកខ្ញុំនៅទីនេះ។ My pen is here.

៤.១.៣ សព្វនាម

- សព្វនាមបុរិសៈ (Personal Pronouns)
  - បុរសទី១

ឧ. ខ្ញុំជាមិត្តភក្តិរបស់វីទូ។ I am Vitou´s friend.

វិទូស្គាល់ខ្ញុំបីឆ្នាំហើយ។ Vitou has known me for three years.

- បុរសទី២

  ឧ. ឯងទៅណា?

- បុរសទី៣

  ឧ. គាត់ជានិស្សិតអក្សរសាស្ត្រខ្មែរ។

- **សព្វនាមឈ្នាប់ (ដែល)**

  ឧ. ខ្ញុំចូលចិត្តអានសៀវភៅ។ សៀវភៅនិយាយអំពីអក្សរសាស្ត្រ។

  ខ្ញុំចូលចិត្តអានសៀវភៅដែលនិយាយអំពីអក្សរសាស្ត្រ។

  អាគីជាឆ្កែដែលខ្ញុំស្រឡាញ់។

  អាគីជាឆ្កែ។ ខ្ញុំស្រឡាញ់ឆ្កែ។

  Aky is a dog. I love the dog.

  Aky is a dog that/which I love.

- **សព្វនាមសំណួរ**

  ឧ. នេះជាអ្វី? (សព្វ.)

នេះជាសៀវភៅអ្វី? (គុ.)

ថ្លៃប៉ុន្មាន? (សព្វ.)

សៀវភៅប៉ុន្មានក្បាល? (គុ.)

- សព្វនាមចង្អុល

  ឧ. នេះជាសៀវភៅ។ This is a book.

  សៀវភៅនេះជារបស់ខ្ញុំ។

  ពួកគេរត់លេងនៅទីនោះ។ They run around over there.

- សព្វនាមមិនច្បាស់

  ឧ. នរណាក៏អាចចូលបណ្ណាល័យបានដែរ។

  ទាំងអស់គ្នាត្រូវតែទៅចូលរួមកម្មវិធី។

  គ្មាននរណាម្នាក់អាចអវត្តមានជាដាច់។

- សព្វនាមឆ្លុះ

  ឧ. ខ្ញុំតែងកំណាព្យខ្លួនឯង។ I write a poem by myself.

  លីនធ្វើម្ហូបខ្លួនគាត់។

៤.១.៤ កិរិយាសព្ទ

- កិរិយាសព្ទសុទ្ធ
- កិរិយាហេតុ (Causative Verb)

  ឧ. គ្រូបង្រៀនសិស្ស។

  រៀន > បង្រៀន

  ហើប > បង្ហើប

  យល់ > ពន្យល់

  ដឹង > ប្តឹង

  ដល់ > ផ្តល់

  ...
- កិរិយាសកម្ម (Transitive Verb)

  ឧ. ខ្ញុំអានសៀវភៅ។
- កិរិយាអកម្ម (Intransitive Verb)

  ឧ. ក្មេងយំ។
- កិរិយាចំណង (Linking Verb)

  ឧ. យើងគឺជានិស្សិត។

ព.ស.ហ.ស
សីល សមាធិ បញ្ញា

គាត់ក្លាយជានាយករដ្ឋមន្ត្រី។

- កិរិយាជំនួយ (auxiliary verb)

  ឧ. ខ្ញុំនឹងក្លាយជាគ្រូបង្រៀន។ I will become a teacher.

  I am going to become a teacher, next year.

៤.១.៥ គុណកិរិយាឬកិរិយាវិសេសន៍ (adverbs)

- គុ.កិ.បំណែប

  ឧ. ខ្ញុំនិយាយយឺតៗ។

- គុ.កិ.កាល

  ឧ. ថ្ងៃនេះ ខ្ញុំទៅបណ្ណាល័យ។

- គុ.កិ.កន្លែង

  ឧ. ខ្ញុំធ្លាប់មកទីនេះ។

- គុ.កិ.សំណួរ

  ឧ. ហេតុអ្វីបានជាអ្នកមិនទៅរៀន?

- គុ.កិ.បរិមាណ

  ឧ. ខ្ញុំហូបតិច។ (គុ.កិ.បរិមាណ)

ព.ស.ហ.ស
សង្ឃ សមាធិ បញ្ញា

ខ្ញុំនិយាយតិច។ (គុ.កិ.បំណែប)

៤.១.៦ ធ្នាក់ (អាយតនិបាត) (Preposition)

ឧ. ខ្ញុំនិយាយជាមួយលីន។ I speak with Lin.

គាត់ជួបនឹងនារីម្នាក់។

៤.១.៧ ឈ្នាប់ (និបាតសព្ទ, សន្ធានសព្ទ) (Conjunction)

ឧ. លីននិងខ្ញុំ

សើចនិងយំ

ល្អនិងអាក្រក់

ខ្ញុំខំរៀន ពីព្រោះខ្ញុំចង់ចេះ។

ខ្ញុំទៅផ្សារដើម្បីទិញម្ហូប។ I went to the market to buy meal.

ខ្ញុំខំរៀនដើម្បីអនាគតល្អ។

៤.១.៨ ឧទានសព្ទ

យី! អើ! អ៎! វ៉ី!

ពូសុខទៅស្រែក្បែរមាត់បឹង។

កន = ពូសុខ

ककि = ទៅស្រែក្បែរមាត់បឹង < កិ=ទៅ + ន=ស្រែ + កមធ=ក្បែរមាត់បឹង < ធ(ក្បែរ) + កន(មាត់បឹង)

សិក្សាប្រៀបធៀប
គុណនាមសំណួរ សព្វនាមសំណួរ និងគុណកិរិយាសំណួរ

- **សព្វនាមសំណួរ** សម្រាប់សួរកប្រធានឬកម្មបទ។

  មាននាទី២យ៉ាង

  - ជំនួសកន្សោមនាមដែលជាចម្លើយនៃសំណួរ
  - បង្កើតល្បះសំណួរ

  មានមុខងារជា

  - ប្រធាន
  - កម្មបទ

  ឧ. **នរណា**កំពុងនិយាយ?

  តើនោះជា**អ្វី**?

  ឯង**មាន**ប៉ុន្មាន?

- **គុណនាមសំណួរ** សម្រាប់សួរកលក្ខណៈរបស់នាមឬចំនួននៃនាម។

  ឧ. តើនោះជាសៀវភៅ**អ្វី**?

  សៀវភៅ**នរណា**នៅលើតុ?

ឯងមានលុយប៉ុន្មាន?

- គុណកិរិយាសំណួរ សម្រាប់បង្កើតល្បះសំណួរ។
  - គុ.កិ.សំណួរកន្លែង

    ឧ. តើឯងរស់នៅឯណា? (Where?)
  - គុ.កិ.សំណួរកាល (When?, What time?)

    ឧ. តើឯងទៅវិញម៉ោងប៉ុន្មាន?
  - គុ.កិ.សំណួរហេតុ (Why?)

    ឧ. ហេតុអ្វីបានឯងមិនទៅរៀន?
  - គុ.កិ.សំណួរបំណែប (How?)

    ឧ. តើឯងគិតដូចម្តេច?
  - គុ.កិ.សំណួរបំណង (Why?, What for?)

    ឧ. តើឯងរៀនដើម្បីអ្វី?

ប្រៀបធៀប

ពាក្យសំណួរ?	សព្វនាមសំណួរ	គុណនាមសំណួរ	គុណកិរិយាសំណួរ
អ្វី?/អ្វីខ្លះ?	នោះជាអ្វី?	នោះជាសៀវភៅអ្វី?	

What?	What is that?	What book is that?	
មួយណា? Which?	មួយណាឯងចង់បាន? Which do you want?	ឯងចង់បានសៀវភៅមួយណា? Which book do you want?	
របស់នរណា? Whose?	នេះជារបស់នរណា? Whose is this?	នេះជាសៀវភៅរបស់នរណា? Whose book is this?	
ហេតុអ្វី? Why?			ហេតុអ្វីឯងគេចរៀន?
ដើម្បីអ្វី?/ព្រោះអ្វី? Why?			ឯងរៀនដើម្បីអ្វី?
នរណា/នរណាខ្លះ? Who? /Whom?	នរណានៅទីនោះ?	នេះជាសៀវភៅនរណា?	
ណា?/ឯណា?			ឯងទៅណា?

Where?			ឯណាសៀវភៅខ្ញុំ?
ពេលណា? When?			ឯងទៅវិញពេលណា?
ដូចម្តេច?/របៀបណា? How?			ឯងគិតដូចម្តេច?
ប៉ុន្មាន? How many? How much?	ឯងមានប៉ុន្មាន?	ឯងមានលុយប៉ុន្មាន?	

*សន្និដ្ឋាន៖

- សព្វនាមសំណួរសួរកនាមដែលមិនស្គាល់ មានចម្លើយជានាមឬកន្សោមនាម។ សព្វនាមសំណួរមានដូចជា អ្វី? អ្វីខ្លះ? នរណា? នរណាខ្លះ? ប៉ុន្មាន? ប៉ុន្មានខ្លះ? មួយណា?
- គុណនាមសំណួរសួរកលក្ខណៈនាម មានចម្លើយជានាមដែលមានមុខងារជាគុណបទ។ គុណនាមសំណួរមានដូចជា អ្វី? អ្វីខ្លះ? នរណា? នរណាខ្លះ? ប៉ុន្មាន? ប៉ុន្មានខ្លះ? គុណនាមសំណួរអាចងាយច្រឡំនឹងសព្វនាមសំណួរ ប៉ុន្តែគុណនាមសំណួរខុសពីសព្វនាមសំណួរត្រង់ថា គុណនាមសំណួរមិនអាចជំនួសឱ្យនាមឬកន្សោមនាមឡើយ តែវាបញ្ជាក់លក្ខណៈឱ្យនាមឬកន្សោមនាមដែលនៅខាងមុខវា។

- គុណកិរិយាសំណួរសួរពេលកាល កន្លែង ហេតុ បំណែប បំណង ។ គុណកិរិយាសំណួរមានដូចជា ពេលណា? ឯណា? ដូចម្តេច? ហេតុអ្វី? ដើម្បីអ្វី? គ.កិ.សំណួរមានចម្លើយជាកន្សោមនាម(Noun Phrase) កន្សោមមានធ្នាក់(Prepositional Phrase) ឬគុណកិរិយា(Adverb Phrase) ដែលមានមុខងារជាកម្មទេសកាល(Adverbials)រួមមាន កម្មកាល កម្មកន្លែង កម្មហេតុ កម្មបំណែប កម្មបំណង និងកម្មភ្នាក់ងារ(the agent)។

  ឧ. តើសៀវភៅសរសេរដោយនរណា? Was this book written by whom?

  សៀវភៅនេះសរសេរដោយលោកបណ្ឌិត កែម ឡី។ (កម្មភ្នាក់ងារ)

  This book was written by Dr. Kem Ley.

  នរណាសរសេរសៀវភៅនេះ? Who wrote this book? (សព្វ.សំណួរ)

  លោកបណ្ឌិតកែមឡី

ព.ស.ប.ស
សីល សមាធិ បញ្ញា

បែបផ្សេងៗពាក្យ

- ពាក្យន័យដូច (សទិសន័យ/ឝវចនសព្ទ)
- ពាក្យន័យផ្ទុយ (បដិន័យ/បដិសព្ទ)
- ពាក្យសូរដូច (សទិសសព្ទ/សទិសសូរ)
- ពាក្យន័យច្រើន (ពហុន័យសព្ទ)
- មហាសព្ទ
- អនុសព្ទ
- បរិវារសព្ទ
- ពាក្យកម្ចី (បាលី-សំស្ក្រឹត, បារាំង, ចិន ...)
- ពាក្យឫស
- ពាក្យផ្សំ

ព.ស.ហ.ស
សីល សមាធិ បញ្ញា

ពាក្យកម្លាយ/ពាក្យក្លាយ??

១. ពាក្យកម្លាយ

អ. derivative word

បារ. mot (m.) dérivé

ពាក្យដែលកើតចេញពីវិធីកម្លាយ, ឧទាហរណ៍ ៖ ប្តឹង < ដឹង + [ប៉-], ឃ្នាប < គាប + [-ន-]។

២. ពាក្យក្លាយ

អ. transformed word

បារ. mot (m.) transformé

ពាក្យដែលបានផ្លាស់ប្តូររូបសព្ទ ខុសប្លែកពីពាក្យដើម ដោយបានឆ្លងកាត់មួយរយៈពេលនៃការប្រើប្រាស់, ឧទាហរណ៍ ៖ -
ក្នុងភាសាខ្មែរ ៖ français > បារាំងសែស > បារាំង,
ភ្នំដូនពេញ > ភ្នំពេញ,...។

-យោង : សទ្ទានុក្រមភាសាវិទ្យានិងអក្សរសិល្ប៍ របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ

សូរវិទ្យា

-សូរវិទ្យាបន្លឺ

-សូរវិទ្យាអាគូស្ទិក

-សូរវិទ្យាឮ

លក្ខណៈខ្សល់

១. សូរខ្សល់ស្ទះគ្មានខ្សល់ មាន ក-គ ច-ជ ដ-ឌ

សូរខ្សល់ស្ទះមានខ្សល់ មាន ខ-ឃ ឆ-ឈ

២. សូរខ្សល់បង្ហូរត្រដុស មាន យ រ ល វ ស ហ ឡ

៣. សូរខ្សល់ច្រមុះ មាន ង ញ ណ ន ម

៤. សូរខ្សល់រែង-ខ្លី

សទ្ទតាវិទ្យា

-សទ្ទតា (Phoneme)

ឧ. ដើរ < ដ+ើ+រ

ផ្តើម < ផ្ត+ើ+ម

ព.ស.ហ.ស
សីល សមាធិ បញ្ញា

ទាំ (ទ័ម)

ទាំង (ទាង់)

ចិត្ត (ចឹត) (coet)

-ព្យាង្គ

ឧ. ដា

-ពាក្យ

ឧ. ដាក់

កើត < ក+ើ+ត (ក ជាសទ្ធដើមព្យាង្គ)

កកើត កកាយ (ក ជាផ្នត់ដើម ជាព្យាង្គ)

កដៃ កជើង (ក ជាពាក្យ)

-រូបសព្ទវិទ្យា

-មូលសព្ទ/មូលតា

ឧ. ប្តឹង < [ប-] + ដឹង

ព.ស.ហ.ស
សីល សមាធិ បញ្ញា

-វចនសព្ទ

ឧ. ដឹង > ប្តឹង, បណ្តឹង, ដំណឹង

-រូបសព្ទ

ឧ. ការសិក្សា

បាតុភូតសូរទាំង៣ក្នុងភាសាខ្មែរ

លំឱនសូរ សម្របសូរ និងទំនាញសូរ

១. លំឱនសូរ : បាតុភូតដែលអានសូរអ៊ិមកជាសូរអេតាមព្យាង្គទី១ ដោយមិនទុកអ៊ិហើយអានអេទេ ប៉ុន្តែកែប្រែសូរអ៊ិឱ្យទៅជាសូរអេសិន តាមរយៈការប្រើប្រាស់សញ្ញាមូសិកទន្ត«ៈ» ។ ឧ. តឹងរឹង < តឹង + រឹង

២. សម្របសូរ : បាតុភូតមួយនៅក្នុងបរិបទសូរវិទ្យា ដែលព្យាង្គមួយត្រូវបានអូសបន្លាយឱ្យឮសូរខ្យល់ព្យញ្ជនៈនៅខាងចុងព្យាង្គផ្លាស់ប្តូរជាព្យញ្ជនៈផ្សេងមួយទៀត។

ឧ. ស្អែក > ស្អែច ឬ ស្អែង, ប៊ិក(Bic) ប៊ិច??

មីង > មីញ

៣. ទំនាញសូរ : បាតុភូតមួយដែលកើតឡើងកាលណាគេសរសេរពួក«អ»អានទៅជា«អ៊ិ» ហើយសរសេរ«អ៊ិ»អានទៅជា«អ» ដោយមិនប្រើប្រាស់សញ្ញាមូសិកទន្ត«ៈ» និងសញ្ញាត្រីសព្វ«ៈ»។ ឧ. ទាហាន ជំហាន ស្រវ៉ា ក្រវិល...។

-យោង : បទសម្ភាសរវាងលោក សយ សុភាព ជាមួយនឹងឯកឧត្តមសាស្ត្រាចារ្យ បណ្ឌិតសភាចារ្យ ច័ន្ទ សំណព្វ អនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា នៅស្ថានីយទូរទស្សន៍BTV នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦

ពាក្យខ្មែរមួយចំនួនប្រកបនឹងខ្យល់<<រ>> តែចេញសូរដូចខ្យល់<<ល>>

ឧ. ករ កណ្តារ ខ្នរ ផុរ យុរ អុរ ហឹរ បង្អុរ សម្បុរ ...។

ចូរ

ចូល

មូលហេតុគឺ ដោយសារពីបុរាណ គេប្រើខ្យល់<<រ>> ដូចខ្យល់ <<ល>> ហើយដោយយើងចង់រក្សាសំណេរបែបចាស់ ឲនៅសល់ផង ក៏ទុកឲនៅដដែល មិនកែខ្យល់ <<រ>> ជា <<ល>> តាមសូរអានជាក់ស្តែង ឬតាមអក្ខរវិធីបច្ចុប្បន្នឡើយ។

*យោង : ឆេង ប៉ែងនិត, វេយ្យាករណ៍ខ្មែរ, ២០២៣

ព.ស.ហ.ស
សីល សមាធិ បញ្ញា

ធាតុវេយ្យាករណ៍សម្រាប់បង្កើតពាក្យក្នុងភាសាខ្មែរ[1]

១. បុព្វបទ ជាធាតុវេយ្យាករណ៍ប្រើសម្រាប់ដាក់នៅខាងដើមពាក្យឬសឬវចនសព្ទដើម្បីឱ្យពាក្យឬសឬវចនសព្ទនោះប្រែប្រួលប្រភេទពាក្យ កម្រិតគុណវុឌ្ឍិ ឬន័យ ។ល។

ដោយយោងតាមតួនាទីរបស់វា បុព្វបទអាចចែកជាបីប្រភេទផ្សេងគ្នា ពោលគឺ *បុរេបទ បុរេសព្ទ* និង *ផ្នត់ដើម* ។

- **បុរេបទ** ជាធាតុវេយ្យាករណ៍ដែលមានលក្ខណៈស្ទើរតែស្វយ័ត ហើយប្រើដាក់នៅខាងដើមវចនសព្ទណាមួយដែលជាគុណនាមឬជាកិរិយាសព្ទ ដើម្បីឱ្យវាក្លាយជានាមសព្ទ ។ បុរេបទ មានជាអាទិ៍ *ការ សេចក្តី ភាព អំពើ* ។

  ឧ . ការរៀនសូត្រ(សកម្មនាម), ភាពល្ងង់ខ្លៅ(សភាវនាម) សេចក្តីល្ងង់ខ្លៅ(សារជាតិនាម), ...។
- **បុរេសព្ទ** ជារូបសព្ទទាំងឡាយណាដែលប្រើដាក់ភ្ជាប់ខាងដើមព្យាង្គនៃវចនសព្ទមួយ ដើម្បីបញ្ជាក់ពីកម្រិតគុណវុឌ្ឍិនៃបញ្ញត្តិ ដែលស្តែងតាមរយៈវចនសព្ទនោះ។ វាពុំមានតួនាទីផ្លាស់ប្តូរប្រភេទពាក្យនៃវចនសព្ទទេ។ បុរេសព្ទ មានជាអាទិ៍ ដូចជា *វិ ទុ សុ បុព្ព បុរេ អតិ ឧប អប្ប* ។ល។ ឧ. សុឆន្ទៈ, អធិរាជ, អតិបរមា, ឧបនាយករដ្ឋមន្ត្រី, ។ល។
- **ផ្នត់ដើម** ជាធាតុវេយ្យាករណ៍ដែលប្រើដាក់នៅខាងដើមព្យញ្ជនៈដើមព្យាង្គនៃឬស ដើម្បីកម្លាយឬសនោះឱ្យកើតបានជាពាក្យថ្មីមួយ។ វាមានលក្ខណៈខុសពីបុរេបទនិងបុរេសព្ទ ដោយសារតែវាមានទម្រង់ច្រើននិងមានតួនាទីទៅតាមទម្រង់នីមួយៗ ហើយលក្ខណៈសម្ព័ន្ធរបស់វាក៏ប្លែកដែរ។ នៅក្នុងទម្រង់នីមួយៗ មានផ្នត់ច្រើន ហើយផ្នត់នីមួយៗត្រូវបានប្រើប្រាស់ដោយអនុលោមទៅតាមឬសដែលយកមកកម្លាយ។

---

[1] ច័ន្ទ សំណព្ធ, បង្កើតពាក្យ កម្ចីពាក្យ បម្រើបម្រាស់ពាក្យ, រាជបណ្ឌិត្យសភាកម្ពុជា, ២០១០

ឧ. [ក-] + កាយ > កកាយ, [ក-] + បាំង > ក្បាំង, [កម់-] + បាំង > កំបាំង

២. អន្តរបទ ជាធាតុវេយ្យាករណ៍ប្រើដាក់នៅចន្លោះពាក្យពីរឬចន្លោះធាតុនៃឬសមួយដើម្បីបង្កើតបានជាពាក្យមួយទៀត។

- ផ្នត់ជែក ជាធាតុនៃវេយ្យាករណ៍ប្រើដាក់នៅចន្លោះធាតុនៃពាក្យឬសមួយ ដើម្បីកម្លាយវាឱ្យកើតបានទៅជាពាក្យថ្មីមួយ។ ដោយអនុលោមតាមលក្ខណៈនៃពាក្យឬសនិងទម្រង់ផ្នត់ដែលគេប្រើ ពាក្យកម្លាយដែលបានមកអាចមានប្រភេទពាក្យដូចគ្នាឬមិនដូចគ្នានឹងពាក្យឬស។

  ឧ. កើត + [-ន-] > ខ្នើត

  ដើរ + [-ម-] > ថ្មើរ

- ស្នៀត ជាធាតុវេយ្យាករណ៍ប្រើសម្រាប់សៀតនៅចន្លោះពាក្យពីរ ដើម្បីឱ្យវាចងសម្ព័ន្ធនឹងគ្នាហើយបង្កើតបានជាពាក្យថ្មីមួយ។

  ឧ. ឥណ្ឌា + ចិន > ឥណ្ឌូចិន

  យាន + ឋាន > យានដ្ឋាន

  អតីត + កាល > អតីតកាល

  សោភ័ណ + ភាព > សោភណភាព

ព.ស.ឃ.ស
សីល សមាធិ បញ្ញា

៣. បច្ឆិមបទ ជាធាតុវេយ្យាករណ៍ប្រើដាក់ខាងចុងពាក្យណាមួយដើម្បីបង្កើតបានជាពាក្យថ្មី។ វាមានលក្ខណៈផ្សេងៗគ្នាទៅតាមប្រភេទរបស់វា។

- បច្ច័យបទ ជាធាតុវេយ្យាករណ៍ប្រើដាក់ខាងចុងពាក្យ ដើម្បីបង្កើតជានាមសព្ទមួយឡើង។ បច្ច័យបទមានជាអាទិ៍ *ភាព ការ កិច្ច កម្ម ករ ការនី* ។ល។

  ឧ. កសិករ កម្មករ វិក្រឹតការ ហត្ថកម្ម សង្គមនិយម

- បច្ច័យសព្ទ ជាធាតុវេយ្យាករណ៍ប្រើសម្រាប់ដាក់ផ្សារភ្ជាប់ទៅនឹងព្យញ្ជនៈចុងព្យាង្គនៃពាក្យណាមួយ ដើម្បីបង្កើតពាក្យថ្មីមួយ។

  *ការប្រើបច្ច័យសព្ទតម្រូវឱ្យមានការរលាយបញ្ចូលគ្នានូវផ្នែកខ្លះរបស់ធាតុផ្សំទាំងពីរ។

  ឧ. នាយ + អក > នាយក

  ឧបាស + អក > ឧបាសក

  ឧបាស + ឥកា > ឧបាសិកា

ព.ស.ហ.ស
សីល សមាធិ បញ្ញា

ព.ស.ហ.ស
សីល សមាធិ បញ្ញា

ទំនាញសូរក្នុងភាសាខ្មែរ

សូរខ្សល់ព្យញ្ជនៈ៨ក្រុម

- ក្រុម១៖ ព្យញ្ជនៈខ្សល់ស្ទះគ្មានខ្សល់៖ ក គ ច ជ ដ ឧ ត ទ ប ព
- ក្រុម២៖ ព្យញ្ជនៈខ្សល់ស្ទះមានខ្សល់៖ ខ ឃ ឆ ឈ ឋ ឍ ឋ ធ ផ ភ
- ក្រុម៣៖ ព្យញ្ជនៈបង្ហូរត្រដុស៖ យ រ ល វ ស ហ ឡ អ
- ក្រុម៤៖ ព្យញ្ជនៈខ្សល់ច្រមុះ៖ ង ញ ណ ន ម

១. ទំនាញសូរកើតឡើង៤កម្រិត

១.១. ការប្រកបសូររវាងព្យ.និងស្រៈ ពោលគឺព្យ.ពួកអ័ទាញស្រៈ ◌ា ◌ិ ◌ី ◌ឹ ។ល។ ដែលមានសូរ អា អិ អី អឹ ។ល។ ឱ្យក្លាយទៅជាសទ្ទតា[2] ដែលមានសូរ អ៊ា អ៊ុ អ៊ឹ ទៅវិញ។

ឧ. ទា ទិ ទី

១.២. ការកែប្រែសូរព្យ.ពីក្រុមអទៅក្រុមអ៊ ដោយការប្រើត្រីសព្ទ ឬការកែប្រែសូរសព្ទព្យ.ពីក្រុមអ៊ទៅក្រុមអ ដោយការប្រើមូសិកទន្ត។

[2] សទ្ទតា ជាសូរដែលបានមកពីការវិភាគសូរផ្សំនៃព្យាង្គឬពាក្យដែលកើតចេញពីការប្រកបសូររវាងព្យញ្ជនៈនិងស្រៈ។ សូរសទ្ទតានេះមិនមានឯករាជ្យពីព្យាង្គឬពាក្យឡើយ ហើយវាខុសពីស្រៈដែលមានឈ្មោះនិងសូរអានដែលវេយ្យាករណិកសន្មតថាមានឯករាជ្យពីព្យាង្គឬពាក្យ។ លក្ខណៈនេះហើយដែលអាចនាំឱ្យភាសាវិទូសន្និដ្ឋានថា ក្នុងភាសាខ្មែរគ្មានស្រៈពួក អ៊ ទេ។

ឧ. ប៊ ស៊ ហ៊ អ៊ ង៉ ញ៉ ប៉ ម៉ យ៉ រ៉ រ៉

*បញ្ជាក់ៈ កម្រិតនេះបូករួមទាំងទំនាញសូរនៃព្យ.«ហ»ទៅលើព្យ.ពួក«អ៊»មួយចំនួនដូចជា «ម ល រ»

ឧ. ហ្ម ហ្មង ហ្លួង ហ្ទូង ចៅហ្វាយ ហ្ម៉ ហ្ម៊ឹង?

១.៣. ការប្រកបសូររវាងព្យ.និងព្យ. ហើយទំនាញសូរនេះត្រូវគោរពតាមច្បាប់មួយច្បាស់លាស់ពោលគឺ៖

- ព្យ.ខ្យល់ស្ទះគ្មានខ្យល់ពួក«អ៊»អាចទាញព្យ.ខ្យល់ស្ទះមានខ្យល់ពួក«អ»

  ឧ. ខ្ជីខ្ជា ឆ្គាំឆ្គង ផ្ទូផ្គង ផ្ទេរ ផ្ទៃ

- ព្យ.ខ្យល់ស្ទះគ្មានខ្យល់និងមានខ្យល់ពួក«អ»ឬ«អ៊» អាចទាញព្យ.ខ្យល់បង្ហូរត្រដុសនិងខ្យល់ច្រមុះពួក«អ៊»ឬ«អ»បាន

  ឧ. ក្រ ក្រុង ខ្លា ខ្លី ខ្ទល់ខ្ទាយ ស្ពុសស្ពាយ ខ្មើត

- ព្យ.ខ្យល់បង្ហូរត្រដុសពួក«អ៊»ឬ«អ»អាចទាញព្យ.ខ្យល់ច្រមុះពួក«អ»ឬ«អ៊»បាន

  ឧ. .ម្សាញ់ ម្សិល ម្សៅ ស្មង ស្មា ស្មាន

- ព្យ.ខ្យល់បង្ហូរត្រដុសពួក«អ»អាចទាញព្យ.ខ្យល់បង្ហូរត្រដុសពួក«អ៊»

  ឧ. ស្ល ស្លា ស្លាប ស្ទា ស្ទាយ ស្រា ស្រៃ ស្រី

*ទំនាញសូរ៣កម្រិតខាងលើមានលក្ខណៈជាខ្មែរ។

សង្ខេបច្បាប់ទំនាញសូរក្នុងភាសាខ្មែរ

- ក្រុម១ទាញក្រុម២/ក្រុម៣/ក្រុម៤
- ក្រុម២ទាញក្រុម៣/ក្រុម៤
- ក្រុម៣ទាញក្រុម៤

១.៤ ការប្រកបសូរវាងព្យាង្គនិងព្យាង្គ អនុវត្តទៅលើពាក្យពីរឬច្រើនព្យាង្គ។ អាស្រ័យលើប្រភេទខ្យល់

- ព្យញ្ជន: ព្យាង្គទី១ដែលមានសូរ«អ» ទាញព្យាង្គទី២ដែលមានសូរ«អ៊» ឱ្យមានសូរដូចខ្លួនបាន។

  ឧ. សម្ល ឬ សំល, សម្រាយ ឬ សំរាយ, កម្រង ឬ កំរង, តម្រា ឬ តំរា, ប្រវែង, ប្រមោយ, ច្រមុះ, ស្រលះ, អន្លាយ, ប្រយោល, បាលី ។ល។

- ព្យញ្ជន: ព្យាង្គទី១ដែលមានសូរ«អ៊ ទាញព្យាង្គទី២ដែលមានសូរ«អ» ឱ្យមានសូរដូចខ្លួនបាន។

  ឧ. គំហើញ ជំហាន ជំហរ ទំហំ ទាហាន

ករណីមិនគោរពតាមច្បាប់ទំនាញសូរ

- ចំពោះពាក្យកម្ចីបាលីសំស្ក្រឹត(២ព្យាង្គ) ជួនកាល គេអនុវត្តតាមច្បាប់ទំនាញសូរដែលមានលក្ខណៈជាខ្មែរ ជួនកាល គេទុកអំណានពាក្យតាមសូរដើម ដោយមិនអនុវត្តតាមច្បាប់ទំនាញសូរឡើយ។

  ឧ. វិហារ* វេហា ង៉ោហារ

  ប្រយោជន៍* ប្រយោល* ប្រយុទ្ធ ប្រយោគ

- ចំពោះពាក្យខ្មែរពីរព្យាង្គមួយចំនួនក៏មិនអនុវត្តតាមច្បាប់ទំនាញសូរដែរ។

  ឧ. អន្លង់ អន្លក់ អន្លើ អន្លាយ*

*កំណត់សម្គាល់៖ ការសរសេរជារាយព្យាង្គក្តី ជាព្យាង្គតម្រួតក្តី មិនទាក់ទងនឹងទំនាញសូរនោះទេ ។ សំណេរពាក្យនិងទំនាញសូរ ជារឿងពីរផ្សេងគ្នា។

ព.ស.ហ.ស
សីល សមាធិ បញ្ញា

ពាក្យ ប្រភេទពាក្យ ថ្នាក់ពាក្យ

- ពាក្យមួយ ប្រៀបទៅនឹង បុគ្គលម្នាក់
- ប្រភេទពាក្យ ប្រៀបទៅនឹង មុខងារដែលបុគ្គលនោះកាន់កាប់

  ប្រភេទពាក្យ គឺអាស្រ័យលើអន្តរកម្មរបស់ពាក្យនោះជាមួយនឹងសហបទរបស់វា។ គ្មានប្រភេទពាក្យណាមួយដែលអាចកើតមានក្រៅអន្តរកម្មនោះទេ។ ហេតុនេះ ការកំណត់ប្រភេទពុំមែនជាការគ្រាន់តែបញ្ចូកពាក្យទៅក្នុងថ្នាក់ពាក្យនោះទេ តែជាការសិក្សាវិភាគពីពាក្យនោះក្នុងគ្រប់ករណីនៃបរិបទប្រើប្រាស់របស់វាជាមុនសិន រួចទាញចេញនូវប្រភេទរបស់វាជាក្រោយ។
- ថ្នាក់ពាក្យ ប្រៀបទៅនឹង វិស័យផ្សេងៗទៅនឹងថ្នាក់ពាក្យ។

មនុស្សម្នាក់អាចជាគ្រូបង្រៀនផង(ឧទាហរណ៍ថាជានាម) ជាមេធាវីផង(ឧទាហរណ៍ថាជាគុណនាម) ជាប្រធានសមាគមផង(ឧទាហរណ៍ថាជាកិរិយាសព្ទ)។ ប៉ុន្តែ គ្រូបង្រៀនមិនមែនជាមេធាវី ហើយក៏មិនមែនជាប្រធានសមាគមដែរ។ គ្រូបង្រៀនស្ថិតក្នុងវិស័យអប់រំ(ថ្នាក់នាម) មេធាវីស្ថិតក្នុងវិស័យច្បាប់(ថ្នាក់គុណនាម) ឯប្រធានសមាគមស្ថិតក្នុងវិស័យមនុស្សធម៌(ថ្នាក់កិរិយា)។

ព.ស.ហ.ស
សីល សមាធិ បញ្ញា

ឧ. (១) ពេលខ្ញុំ**ធំ**ឡើង ខ្ញុំចង់ក្លាយជាគ្រូបង្រៀន។

(២) នំមិន**ធំ**ជាងនាឡិ។

(៣) គាត់មានផ្ទះ**ធំ**មួយ។

(៤) វាចាយ(លុយ)**ធំ**ណាស់។

(១)និង(២)មានប្រភេទពាក្យជាកិរិយាសព្ទ

(៣)មានប្រភេទពាក្យជាគុណនាម

(៤)មានប្រភេទពាក្យជាគុណកិរិយា

(១) ផ្ទះ**ល្អ**លក់បានថ្លៃ។

(២) ផ្ទះនេះ**ល្អ**ណាស់។

(៣) ធ្វើ**ល្អ** បាន**ល្អ** = ធ្វើបុណ្យ បានបុណ្យ

(១)មានប្រភេទពាក្យជាគុណនាម

(២)មានប្រភេទពាក្យជាកិរិយាសព្ទ

(៣)មានប្រភេទជាកម្មបទផ្គាល់

(១) **ខ្ញុំ**ទិញផ្ទះមួយ។

ព.ស.ហ.ស
សីល សមាធិ បញ្ញា

(២) ផ្ទះ**ខ្ញុំ**ធំណាស់។

(១)មានប្រភេទពាក្យជាសព្វនាមបុរសទី១

(២)មានប្រភេទពាក្យគុណនាមកម្មសិទ្ធិ

(១) **ឈ្មោះ**ឯងពីរោះណាស់។

(២) ឯង**ឈ្មោះ**អ្វី?

(១)មានប្រភេទពាក្យជានាម

(២)មានប្រភេទពាក្យជាកិរិយាសព្ទ

ព.ស.ហ.ស
សីល សមាធិ បញ្ញា

ភាពខុសគ្នារវាងនាមសព្ទដែលកើតដោយប្រើបុរេបទ«ការ»
និងនាមសព្ទដែលកើតឡើងដោយផ្នត់ជែក [-អ៉ម/ណ-]

១. ភាពខុសគ្នារវាង *ការទិញ* និង *ទំនិញ*

-ការទិញ ជាសកម្មនាម ស្តែងពីអំពើ

-ទំនិញ ជាសារធាតុនាម ស្តែងពីរបស់ដែលទិញហើយ

គេមិនអាចជំនួញ«ទំនិញ»ដោយ«ការទិញ»បានទេ។ គេអាចនិយាយថា **ការទិញទំនិញ** តែគេមិនអាចនិយាយថា **ទំនិញការទិញ** បានទេ។

២. ភាពខុសគ្នារវាង *ការចេញ* និង *ចំណេញ*

-ការចេញ ជាសកម្មនាម

-ចំណេញ ជាសារធាតុនាម

បើគេនិយាយពី«ការចេញលុយ»គឺនិយាយពីការចំណាយប្រាក់ តែបើគេនិយាយពី«ការចំណេញលុយ»វិញ គឺគេនិយាយពីការបានទទួលលុយជាប្រាក់ចំណូលទៅវិញ។

ម្យ៉ាងទៀត «ការចេញលុយ» ជាកន្សោមនាម ឯ «ចំណេញលុយ» ជាកន្សោមកិរិយាសព្ទ

៣. ភាពខុសគ្នារវាង *ការចាយ* និង *ចំណាយ*

-ការចាយ ស្តែងពីការបង់ប្រាក់ទៅលើតម្លៃទំនិញឬសេវាដែលយើងបានជាវ។

-ចំណាយ អាចជានាមឬកិរិយាសព្ទ។ បើវាជានាមសព្ទ វាបញ្ជាក់ពីចំនួនប្រាក់ដែលយកទៅចាយ។

៤. ភាពខុសគ្នារវាង *ការសង* និង *សំណង*

-ការសង ជាការប្រគល់អ្វីដែលគេបានខ្ចីទៅឱ្យម្ចាស់ដើមវិញ

-សំណង ជាលុយឬជាវត្ថុដែលត្រូវយកទៅសងគេ។

៥. ភាពខុសគ្នារវាង *ការគរ* និង *គំនរ*

-ការគរ ស្តែងពីសកម្មភាព

-គំនរ ស្តែងពីលទ្ធផល

គេនិយាយថា៖

-គំនរសំរាមកើតមកពីការគរសំរាម

-ការគរសំរាមនាំឱ្យមានគំនរសំរាម

ប៉ុន្តែ គេមិនអាចនិយាយថា៖

-គំនរសំរាមនាំឱ្យមានការគរសំរាម។

-ការគរសំរាមកើតមកពីគំនរសំរាម។

៦. ភាពខុសគ្នារវាង *ការកាត់* និង *កំណាត់*

-ការកាត់ ជាទង្វើឬអំពើរបស់មនុស្សដែលត្រូវចំណាយថាមពលដើម្បីឱ្យការកាត់នោះបានសម្រេច

ត.ស.ហ.ស
សីល សមាធិ បញ្ញា

-កំណាត់ បានមកពីការកាត់

កំណាត់ដំបង ខុសការពី ការកាត់ដំបង ។ បើគេកាត់ដំបងមួយ គេបានដំបងពីរកំណាត់។

គេនិយាយថា «ដំបងពីរកំណាត់» តែគេមិនអាចនិយាយថា «ដំបងពីរការកាត់» នោះទេ។

គេនិយាយថា «បើគេកាត់ដំបងមួយជាកំណាត់» តែមិននិយាយថា «បើគេកាត់ដំបងមួយជាការកាត់» នោះទេ។ បើការកាត់មានចំនួន១ដងនោះ គេបានពីរកំណាត់ តែបើការកាត់មាន២ដង គេបានបីកំណាត់។

៧. ភាពខុសគ្នារវាង *ការខុស* និង *កំហុស*

-ការខុសច្បាប់ គឺការប្រព្រឹត្តល្មើសនឹងច្បាប់ ដែលការប្រព្រឹត្តនោះ ជាចេតនាឬអចេតនានៃបុគ្គលណាម្នាក់។

-កំហុសច្បាប់ គឺជាការខ្វះចន្លោះនៃច្បាប់។

ព.ស.ហ.ស
សីល សមាធិ បញ្ញា